**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរដ្ឋប្បវេណីលេខ ២២៩
ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០
សាលក្រមរដ្ឋប្បវេណីលេខ៖ ២២ "ជជ"
ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាល បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ លើសំណុំរឿងរដ្ឋប្បវេណីលេខ២២៩ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**សហដើមចោទ**

១-ឈ្មោះ [redacted] ផូរហុង ភេទប្រុស ឆ្នាំកំណើត១៩៦៨ មុខងារ មន្ត្រីរាជការ មានទីលំនៅបច្ចុប្បន្ន [redacted]។

២.ឈ្មោះ [redacted] ជានី ភេទស្រី ឆ្នាំកំណើត១៩៧០ មុខរបរ ធ្វើស្រែ មានទីលំនៅបច្ចុប្បន្ននៅ [redacted]

ដោយមានលោកស្រីមេធាវី [redacted] អត្តលេខ ៥៥៥១ ជាមេធាវីតំណាងដោយអាណត្តិឱ្យសហដើមចោទ មានការិយាល័យនៅក្រុមមេធាវី [redacted]។

និងមេធាវី [redacted] អត្តលេខ ៨៣១ ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ជានី មានការិយាល័យ [redacted]។

**ចុងចម្លើយ**

-ឈ្មោះ [redacted] សុវណ្ណ ភេទប្រុស ឆ្នាំកំណើត១៩៦៨ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] (បច្ចុប្បន្នកំពុងជាប់ឃុំនៅពន្ធនាគារខេត្តកណ្តាល)។

ដោយមានមេធាវី [redacted], [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ។

**កម្មវត្ថុនៃបណ្តឹង** ៖ ប្តឹងសុំឱ្យមោឃភាពលិខិតផ្ទេរសិទ្ធិ។

# អង្គហេតុ និង ចំណុចទទាត

## ១-សាលក្រមដែលទាមទារដោយដើមចោទៈ

១.១- សុំមោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ៦២២ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ម៉េងឡុង ទំហំ ១២៥ ហិចតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

១.២- សុំមោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ៥០ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] លីសាន ទំហំ ១០ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

១.៣- មោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ៣៥១ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ធារ៉ូ ទំហំ ១៥ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

១.៤- មោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥២ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ឡាឌីន ទំហំ ១០ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

១.៥- មោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥៣ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] សុគន្ធា ទំហំ ២០ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

១.៦- មោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥៥ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ម៉េងឡុង ទំហំ ៣០ ហិចតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

១.៧- មោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥៦ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ជាន់ណា ទំហំ ១៥ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

១.៨- ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយឈ្មោះ [redacted] សុវណ្ណ។

១.៩- អាចអនុវត្តជាបណ្តោះអាសន្ន។

**ការស្នើសុំបន្ថែមនូវកម្មវត្ថុនៃបណ្តឹងៈ**

ក. ស្នើសុំឱ្យទទួលស្គាល់ដីដែលមានទំហំ ៥៥៧២១២ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិអង្គរជ័យ ភូមិកណ្តាលលើ និងភូមិកណ្តាលក្រោម នៃឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលបានវាស់វែងជាមួយក្រុមចម្រុះរបស់ស្រុកដែលមាន ៖

១. អ័ក្សអាប់ស៊ីស (X)៥១៣៩៥៣ និងកូអ័រដោណេ (Y)១២៥២៥៤០
២. អ័ក្សអាប់ស៊ីស (X)៥១៥០៥៨ និងកូអ័រដោណេ (Y)១២៥៧៤៩៣
៣. អ័ក្សអាប់ស៊ីស (X)៥១៥៥៧៣ និងកូអ័រដោណេ (Y)១២៥៧៤៥៦
៤. អ័ក្សអាប់ស៊ីស (X)៥១៥៥៧៤ និងកូអ័រដោណេ (Y)១២៥៧៤៥៦
៥. អ័ក្សអាប់ស៊ីស (X)៥១៥០៧៤ និងកូអ័រដោណេ (Y)១២៥៧២២៦



Scanned with CamScanner

៦. អ័ក្សអាប់ស៊ីស (X)៥១៥០៧៥ និងកូអ័រដោណេ (Y)១២៥៧២២៦

៧. អ័ក្សអាប់ស៊ីស (X)៥១៣៩៦៩ និងកូអ័រដោណេ (Y)១២៥៧០៦៦ ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ផានី។

ខ. ស្នើសុំបង្គាប់ឱ្យមន្ទីរសុរិយោដីធ្វើការចុះបញ្ជីដីដែលមានទំហំ **៥៥៧២១២** ម៉ែត្រការ៉េ ខាងលើនេះ មកជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ផានី។

**២- ការពន្យល់អំពីរឿងក្តី**

កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ សហដើមចោទ បានដាក់ពាក្យបណ្តឹងមកតុលាការដោយបញ្ជាក់អង្គហេតុថា សហដើមចោទ [redacted] ជូរហុង បានគ្រប់គ្រង អាស្រ័យផលនៅលើដីទំហំ ៦៨ ហិចតា រួមទាំងដីផ្សេងទៀត ដែលខ្លួនបានប្រមូលទិញដោយស្របច្បាប់ពីប្រជាពលរដ្ឋនៅភូមិខ្សុំ ភូមិអង្គជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដោយមានលិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះហត្ថលេខា ទទួលស្គាល់នៅអាជ្ញាធរដែនដីភូមិ-ឃុំ ដែលគ្រប់គ្រងនៅមូលដ្ឋានផ្ទាល់ ហើយដែលរូបខ្លួន គ្រប់គ្រងរហូតមកមិនដែលអាក់ខាន ចាប់តាំងពីឆ្នាំ២០១០,២០១២ រហូតមកដល់បច្ចុប្បន្ននេះ មិនដែលអាក់ខានឡើយ។ ស្រាប់តែនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ ខ្លួនបានឃើញឈ្មោះ [redacted] សុវណ្ណ ទៅបញ្ជាឱ្យគេដឹកបង្គោលថ្មយកទៅដឹកកប់នៅលើដីរបស់ខ្លួនដោយព័ទ្ធចូលក្នុងដីរបស់ខ្លួនទំហំ ៦៨ ហិកតា និងចូលទៅក្នុងដីរបស់ឈ្មោះ [redacted] ផានី និងដីរបស់ឈ្មោះ [redacted] ម៉េង ខ្លះ ពេលនោះខ្លួន និងប្រជាពលរដ្ឋនៅទីនោះចំនួន ០២នាក់ទៀត មានឈ្មោះ [redacted] ឆាង និងឈ្មោះ [redacted] ថា បានឃាត់មិនឱ្យបោះបង្គោលលើដីរបស់ខ្លួនទេ ព្រោះដីខ្លួនមានប្រឡាយព័ទ្ធជុំវិញ ហើយខ្លួនកាន់កាប់ ជាយូរមកហើយ ពេលនោះឈ្មោះ [redacted] សុវណ្ណ បានស្រែកឡូឡាប្រមាថដល់អាយុជីវិតរបស់ឈ្មោះ [redacted] ឆាង ហើយឈ្មោះ [redacted] ម៉េងឡុង ដែលជាអ្នកទិញដីរបស់ខ្លួនពីឈ្មោះ [redacted] សុវណ្ណ បានឆ្លើយថា គាត់ទិញដីនេះពីឈ្មោះ [redacted] សុវណ្ណ នៅចុងឆ្នាំ២០១៧ ហើយកាលនោះទឹកលិច ជិះទូកមកមើល មិនបានឃើញដីទេ ឃើញតែទឹក ដោយលោក [redacted] សុវណ្ណ អះអាងថាដីនេះជាដីរបស់ភូមិភាគ ហើយបានលក់ឱ្យខ្លួនឈ្មោះ [redacted] ម៉េងឡុង ទំហំ ១២៥ ហិកតា ក្នុងមួយហិកតាតម្លៃ ២៥០០ដុល្លារ ដោយធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះហត្ថលេខា ដល់អាជ្ញាធរស្រុក ហើយឱ្យគាត់បង់ប្រាក់ចំនួន ៩០% ខែកុម្ភៈ ឆ្នាំ២០១៨ ទើបសន្យាចុះបោះបង្គោលព្រំ ហើយបង់ប្រាក់បន្ថែម១០%ទៀត បង្គ្រប់ ១០០% ប៉ុន្តែចេះតែមានការពន្យារពេលរហូតដល់ខែឧសភា ឆ្នាំ២០១៨ នេះ ពេលបុណ្យចម្រើនព្រះជន្ម ទើបបានចុះបោះបង្គោល ហើយឈ្មោះ [redacted] ម៉េងឡុង ក៏បានបញ្ជាក់ដែរថា ពេលចុះមកបោះបង្គោលលើដីនេះ ដែលជាពេលទឹកគោក ទើបគាត់ មើលឃើញច្បាស់ថា ដីនេះ ពិតជាដីរបស់ខ្លួន [redacted] ជូរហុង និងដីរបស់លោកស្រី [redacted] ផានី ទេ តែឈ្មោះ [redacted] សុវណ្ណ នៅតែអះអាងថា ដីនេះជាដីរបស់ភូមិភាគ ដែលតាមការពិតនរណាក៏គេដឹងច្បាស់ថា ដីរបស់ភូមិភាគ គឺស្ថិតនៅចំងាយពីដីនេះ ៤០០ ទៅ ៥០០ ម៉ែត្រឯណោះ។ ឈ្មោះ [redacted] ម៉េងឡុង បានប្រាប់ខ្លួនថា ដីនេះគាត់ទិញចុងឆ្នាំ២០១៧ តែអាជ្ញាធរស្រុកបានហៅមេឃុំ ឱ្យចុះហត្ថលេខា ដោយចុះថ្ងៃខែដាក់ឆ្នាំ២០១៦ ហើយគាត់បានណាត់ខ្លួន [redacted] ជូរហុង មកជួបជុំគ្នាពិនិត្យឯកសារនៅផ្សារ TK ជិតរង្វង់មូលទួលគោក ដើម្បីគាត់ទារប្រាក់ពីឈ្មោះ [redacted] សុវណ្ណ វិញ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨ ខ្លួន និងឈ្មោះ [redacted] ម៉េងឡុង និងឈ្មោះ [redacted] ផានី ក៏បានមកជួបជុំ ហើយបាននិយាយពីការហួសចិត្តដែលលោក [redacted] សុវណ្ណ លួចលក់ដីរបស់ខ្លួន និងដី



Scanned with CamScanner

របស់ឈ្មោះ [redacted] ផានី នេះ ខ្លួនក៏ប្តឹងមកអយ្យការអមសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨។

**៣. សេចក្តីថ្លែងការណ៍របស់គូភាគី**

-ដើមចោទឈ្មោះ [redacted] ផានី ៖ ខ្ញុំទុកសិទ្ធិឱ្យមេធាវីរបស់ខ្ញុំ ធ្វើសេចក្តីថ្លែងការណ៍ជំនួសខ្ញុំ។

-មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ធ្វើសេចក្តីថ្លែងការណ៍ថា៖ កូនក្តីនាងខ្ញុំស្នើសុំឱ្យតុលាការសម្រេចដូចខាងក្រោម ៖

១. សុំមោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ៦២២ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ម៉េងឡុង ទំហំ ១២៥ ហិចតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

២. សុំមោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ៥០ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] លីសាន ទំហំ ១០ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៣. មោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ៣៥១ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ធារ៉ូ ទំហំ ១៥ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៤. មោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥២ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ឡាឌីន ទំហំ ១០ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៥. មោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥៣ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] សុគន្ធា ទំហំ ២០ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៦.មោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥៥ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ម៉េងឡុង ទំហំ ៣០ ហិចតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៧. មោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥៦ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ផាន់ណា ទំហំ ១៥ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

ទាក់ទងនឹងការស្នើសុំមោឃភាពចោលលិខិតផ្ទេរសិទ្ធិទាំងនេះ ព្រោះដោយហេតុថា ទី១ ឈ្មោះ [redacted] សុវណ្ណ គាត់មិនមានដីស្ថិតនៅលើដីដែលគាត់បានផ្ទេរសិទ្ធិទៅឱ្យអ្នកទាំង០៧នាក់នោះទេ, ទី២ ដីទំហំ ១២៥ ហិចតានេះ គឺឈ្មោះ [redacted] សុវណ្ណ គាត់ផ្ទេរសិទ្ធិទៅឱ្យឈ្មោះ [redacted] ម៉េងឡុង ទំហំ ១២៥ ហិចតា ហើយគាត់បានផ្ទេរសិទ្ធិឱ្យអ្នកទាំង០៦នាក់ទៀត នោះពុះជាចំណែកតូចៗ នៅលើទំហំដី ១២៥ហិចតា ដែលគាត់ផ្ទេរជាន់គ្នាដដែល។ ទាក់ទងនឹងឯកសារដែលនាងខ្ញុំស្នើសុំមោឃភាពលិខិតផ្ទេរសិទ្ធិនេះ យើងខ្ញុំមានភស្តុតាងដែលដាក់ជូននៅក្នុងនីតិវិធីត្រៀមរួចហើយ នាងខ្ញុំស្នើសុំ ឯកឧត្តមប្រធាន មេត្តាពិនិត្យភស្តុតាងដែលនាងខ្ញុំបានដាក់ជូននេះ។ យើងមានលិខិតបដិសេធជាផ្លូវការរបស់លោកមេឃុំ [redacted] ជា



Scanned with CamScanner

មេឃុំបន្ទាយដែក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ ដែលគាត់បានបញ្ជាក់អំពីឈ្មោះ [redacted] សុវណ្ណ ដែលជាចុងចម្លើយនេះ គាត់មានចេតនាបង្ខំគាត់ ដើម្បីយកដីដដែលទៅឱ្យគាត់ផ្ទេរសិទ្ធិជាន់គ្នា។ ទីតាំងដីរបស់ដើមចោទឈ្មោះ [redacted] ជូរហុង គឺស្ថិតនៅក្នុងភូមិខ្សុំ (បច្ចុប្បន្នអង្គរជ័យ)។ លោក [redacted] ជូរហុង គាត់បានដាក់លិខិតផ្ទេរសិទ្ធិដីធ្លី ចំនួន ១៩ ហិចតា ដែលគាត់បានទិញពីប្រជាពលរដ្ឋ ដោយមានភូមិឃុំទទួលស្គាល់ដឹងឮត្រឹមត្រូវ ដែលលិខិតទាំងនេះ បានដាក់ជូនជាភស្តុតាងជូនតុលាការរួចហើយ។ ដីដែលឈ្មោះ [redacted] សុវណ្ណ គាត់ធ្វើលិខិតប្រគល់លក់ជាន់គ្នា ១២៥ ហិចតានេះ គាត់ដាក់ទីតាំងដែលគាត់លក់នោះនៅភូមិកណ្តាលលើ ប៉ុន្តែនៅពេលដែលវាស់យកដី គឺវាស់យកដីនៅភូមិអង្គរជ័យ ដែលដីនេះកាន់កាប់គ្រប់គ្រងដោយដើមចោទតាំងពីឆ្នាំ២០១០ រហូតដល់បច្ចុប្បន្ននេះ ក៏ដើមចោទនៅតែគ្រប់គ្រងនេះ។ ទីតាំងដីពិតប្រាកដ ដែលទំនាស់គ្នា ទំហំ ១២៥ ហិចតា នេះ ជាដីរបស់ឈ្មោះ [redacted] ជូរហុង ស្ថិតនៅភូមិអង្គរជ័យ (អតីតភូមិខ្សុំ)។ ដីដែលឈ្មោះ [redacted] សុវណ្ណ គាត់វាស់លក់ឱ្យគេនោះ គឺគាត់វាស់ចូលទៅដីរបស់ឈ្មោះ [redacted] ជូរហុង ប្រហែល ៦ ទៅ៧ ហិចតា និងចូលដីរបស់ឈ្មោះ [redacted] ផានី ប្រហែល ៥០ ហិចតា។

-ដើមចោទឈ្មោះ [redacted] ផានី បានអះអាងថា ដីរបស់ខ្ញុំទំហំជាង ៥០ហិចតា។

-មេធាវី [redacted] បានថ្លែងការណ៍ថា ៖ ខ្ញុំសូមបញ្ជាក់បន្ថែមទាក់ទងនឹងការចុះទៅវាស់ដី ដែលមានអាជ្ញាធរចូលរួម ដែលមានអក្សរអាប់ស៊ីស និងអក្សរអរដោណេរួចហើយ ដែលនាងខ្ញុំបានដាក់ជូនភស្តុតាងរួចហើយ នៅក្នុងសំណុំរឿងនេះ។ នៅក្នុងដីរបស់ឈ្មោះ [redacted] ផានី នេះ គឺទំហំដី ៥៥ ហិចតា ៧២ អា ដែលគាត់បានធ្វើការវាស់វែងដោយមានការចូលរួមពីអាជ្ញាធរខេត្ត លើទំហំដី និងទីតាំងដីនេះ។

-មេធាវី [redacted] បានថ្លែងការណ៍ថា ដីរបស់ឈ្មោះ [redacted] ជូរហុង ទំហំ ៦៨ ហិចតា។

-ចុងចម្លើយឈ្មោះ [redacted] សុវណ្ណ ថ្លែងការណ៍ថា ៖ ដីរបស់ខ្ញុំសរុបទំហំ ១២៥ ហិចតា ស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ។ ដីរបស់ខ្ញុំមានអាជ្ញាធរភូមិឃុំ និងស្រុក ទទួលស្គាល់ មានឯកសារត្រឹមត្រូវ។ លោកអភិបាលខេត្ត គាត់បានឱ្យមន្ត្រីសុរិយោដីខេត្តចុះទៅពិនិត្យជាមួយលោកអភិបាលរងមួយទៀត និងសុរិយោដីស្រុក ចុះទៅដល់ទីតាំងដី ហើយលោកក៏បានឯកភាព ការកាយដីនេះ គឺត្រួតលើគ្នា។ លោកស្រី [redacted] ផានី និងលោក [redacted] ជូរហុង នេះ គាត់ទើបតែទៅកាយដីនៅឆ្នាំ ២០១៩ ខែ០៥ នេះទេ គាត់គ្មានឯកសារអ្វីទាំងអស់ ហើយដីខ្ញុំនេះ គឺកំពុងតែដោះស្រាយគ្នានៅគណៈកម្មការខេត្ត ដោយមានឯកឧត្តម [redacted] សោភ័ណ្ឌ ជាអ្នកដោះស្រាយ ព្រោះខ្ញុំបានប្តឹងមិនឱ្យចុះបញ្ជីធ្វើប្លង់។ ខ្ញុំក៏បានប្តឹងទៅដល់ក្រសួងទៀត ដូច្នេះ រឿងខ្ញុំនេះ កំពុងតែដោះស្រាយនៅគណៈកម្មការខេត្តបច្ចុប្បន្ននេះ។ ខ្ញុំមានឯកសារត្រឹមត្រូវ។ ដីរបស់ខ្ញុំស្ថិតនៅភូមិកណ្តាលលើ ចំណែកដីរបស់ឈ្មោះ [redacted] ជូរហុង ស្ថិតនៅភូមិខ្សុំ។ បច្ចុប្បន្ន គេមិនមានបំបែកភូមិអ្វីនោះទេ បើសិនជាគាត់ថាមានការបំបែកភូមិ ខ្ញុំបាទស្នើសុំលិខិតស្នាមបំបែកភូមិដែលអាជ្ញាធរដឹងឮ។ ដីរបស់ខ្ញុំ នៅភូមិកណ្តាលលើ ដីរបស់ឈ្មោះ [redacted] ជូរហុង នៅភូមិខ្សុំ និងដីរបស់ឈ្មោះ [redacted] ផានី នៅភូមិកណ្តាលលើដែរ។ គាត់ចេះតែចោទប្រកាន់ខ្ញុំ។ ភូមិទាំងពីរនេះ គឺនៅជាប់គ្នា ហេតុនេះហើយ បានជាខ្ញុំបាទប្តឹងដល់ខេត្ត។ ដីរបស់ខ្ញុំ មានអាជ្ញាធរភូមិឃុំ ស្រុក ទទួលស្គាល់ដឹងឮ។ ខ្ញុំនឹងដាក់ឯកសារជូនតុលាការ។ ដីទំហំ ១២៥ ហិចតា នេះ ខ្ញុំបានសុំរដ្ឋកាន់កាប់តាំងពីឆ្នាំ១៩៩៨ ខ្ញុំបានចូលកាន់កាប់តាំងពីមុនគេបំផុត។

-មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានថ្លែងការណ៍ថា ៖ នៅក្នុងរឿងនេះ ខ្ញុំសូមការអនុញ្ញាតជម្រាបជូន ឯកឧត្តមប្រធាន អំពីពាក្យបណ្តឹង នៅក្នុងរឿងនេះ ពាក្យ

បណ្តឹងស្នើសុំមោឃភាពដូចសហភាគា បានលើកឡើង ភាគីបានស្នើសុំមោឃភាពប័ណ្ណ មានន័យថា សុំមោឃភាពឯកសារការផ្ទេរសិទ្ធិរបស់កូនក្តីខ្ញុំបាទចំនួន ០៧ ប័ណ្ណ ដែលឯកសារទាំងអស់នេះ ធ្វើឡើង ដោយអាជ្ញាធរដល់ថ្នាក់ស្រុក។ ការស្នើសុំរបៀបនេះ តាំងពីនីតិវិធីត្រៀមលើកទី១ នីតិវិធីត្រៀមលើកទី២ ខ្ញុំនៅតែស្នើសុំឱ្យតុលាការធ្វើការកែតម្រូវលើពាក្យបណ្តឹងទាំងនេះ ដោយមូលហេតុថា ពាក្យបណ្តឹងនេះ ជាពាក្យបណ្តឹងផ្ទុយច្បាប់ មានន័យថា មិនមានចំណុចមួយណា ដែលអនុញ្ញាតឱ្យភាគីស្នើសុំ មោឃភាព ទៅលើឯកសាររបស់អាជ្ញាធរ ដែលធ្វើឡើងដោយអាជ្ញាធរនោះទេ។ ទី២ ឯកសារទាំងនេះ គឺជាឯកសារ ដែលធ្វើឡើងរវាងកូនក្តីខ្ញុំ និងជាមួយភាគីអ្នកទិញ ដោយធ្វើឡើងដោយឯកជន និងឯកជន មានការទទួល ស្គាល់ដោយសមត្ថកិច្ច។ សំណុំរឿងរដ្ឋប្បវេណីអនុវត្តទៅបាន លុះត្រាតែសិទ្ធិរបស់អ្នកនោះ មាននៅក្នុង ច្បាប់ ចែងនៅក្នុងក្រមរដ្ឋប្បវេណី ប៉ុន្តែការស្នើសុំមោឃភាពនេះ មិនមានចែងអំពីសិទ្ធិនេះ នៅក្នុងក្រមរដ្ឋ ប្បវេណីទេ។ ដូច្នេះ នៅក្នុងនីតិវិធីត្រៀមលើកទី១ លើកទី២ ខ្ញុំនៅតែព្យាយាមស្នើសុំឱ្យតុលាការធ្វើការ កែតម្រូវ ឬ ក៏លើកចោលពាក្យបណ្តឹងនេះ ដោយសារមូលហេតុ ពាក្យបណ្តឹងផ្ទុយច្បាប់។ នេះជាចំណុច ដែលខ្ញុំស្នើសុំឯកឧត្តមប្រធានមេត្តាពិចារណា ឱ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ ដោយសារភាគី តាមការ យល់របស់ខ្ញុំ ភាគីវិវាទអំពីកម្មសិទ្ធិនៅលើដី ប៉ុន្តែកូនក្តីខ្ញុំបានលើកឡើងអំបាញ់មិញនេះ សិទ្ធិទាំងអស់នេះ ត្រូវបានកំពុងដោះស្រាយវិវាទនៅគណៈកម្មការដោះស្រាយវិវាទដីធ្លី។ ទី២ សំណុំរឿងនេះ ត្រូវបានភាគី ដើមចោទ ធ្វើការចោទកូនក្តីខ្ញុំបាទ ថាកាន់កាប់អចលនវត្ថុអ្នកដទៃ ហើយកំពុងដំណើរការ សំណុំរឿងនេះ នៅតុលាការព្រហ្មទណ្ឌ មិនទាន់បានចប់។ ស្រាប់តែមានការស្នើសុំមោឃភាពទៅលើឯកសារផ្ទេរសិទ្ធិ របស់កូនក្តីខ្ញុំបាទនេះ។ ខ្ញុំសំណូមពរ សុំឱ្យឯកឧត្តមប្រធាន ពិចារណា ថាតើបណ្តឹងនេះ ស្របច្បាប់ ឬមិនទាន់ស្របច្បាប់? ខ្ញុំឃើញថា នៅក្នុងកំណត់ហេតុនៅក្នុងនីតិវិធីត្រៀម ត្រង់ចំណុចវិវាទ គឺ ចំណុចទី១ តើការស្នើសុំមោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ចំនួន ០៧ ច្បាប់របស់ដើមចោទ មាន លក្ខណៈត្រឹមត្រូវ ដែរ ឬ ទេ? ថាតើឯកសារនេះ ត្រឹមត្រូវ ឬ ទេ ដូច្នេះ មិនទាន់ត្រូវលើកអំពីសិទ្ធិ អ្នកណា កាន់កាប់ អ្នកណាមានសិទ្ធិ ដែលត្រូវលើកមកបង្ហាញតុលាការនាពេលនេះទេ។ ខ្ញុំស្នើសុំ ឯកឧត្តមប្រធាន មេត្តាពិចារណា ថា តើពាក្យបណ្តឹងស្របច្បាប់ ដែលគួរតុលាការ លើកយកមកពិចារណា ដែរឬទេ? *ប្រសិនជា ឯកឧត្តមប្រធាន យល់ឃើញថា ជាការស្របច្បាប់ ខ្ញុំស្នើសុំ ឯកឧត្តមប្រធាន បន្តនីតិវិធីទៅ* ពេលក្រោយ ឬនៅពេលណា ទៅតាមការសម្រេចរបស់ ឯកឧត្តមប្រធាន បើមិនស្របច្បាប់ទេ ខ្ញុំបាទ ស្នើសុំឱ្យ ឯកឧត្តមប្រធាន លើកបណ្តឹងនោះចោល។ ប្រសិនបើ ឯកឧត្តមប្រធាន លើកយករឿងនេះបន្ត ខ្ញុំ បាទមិនមានអ្វីស្នើសុំបន្ថែមទេ ដោយហេតុថា បណ្តឹងនេះ វាស្ថិតនៅក្នុងបណ្តឹងផ្ទុយច្បាប់ ខ្ញុំរក្សាសិទ្ធិ ក្នុងការការពារការយល់ឃើញរបស់ខ្ញុំបាទ។

-មេធាវី [redacted] ធ្វើសេចក្តីថ្លែងការណ៍តបថា ៖ ចំពោះលក្ខខណ្ឌនៃបណ្តឹងដែលលោកមេធាវី លើកឡើង គឺជាការមិនត្រឹមត្រូវតាមនីតិវិធីទេ ដោយសារតែ ឯកសារដែលយើងខ្ញុំស្នើសុំមោឃភាពនេះ គឺមិនមែនជាបញ្ហាបណ្តឹង គឺជាលិខិតផ្ទេរសិទ្ធិកាន់កាប់ហើយ ឯកសារលិខិតផ្ទេរសិទ្ធិកាន់កាប់ របស់ចុង ចម្លើយធ្វើនេះ គឺមិនត្រឹមត្រូវតាមលក្ខខណ្ឌច្បាប់ទេ ដោយសារ ទី១ ចុងចម្លើយ គាត់គ្មានដី គ្មានឯកសារ បញ្ជាក់ថា ខ្លួនជាម្ចាស់គ្រប់គ្រងលើដីនោះទេ។ ទី២ ចុងចម្លើយនេះ បានយកដីមួយកន្លែងនេះផ្ទេរសិទ្ធិទៅ ឱ្យបុគ្គលច្រើននាក់ នៅលើដីតែមួយកន្លែង ហេតុនេះ ចុងចម្លើយធ្វើខុសច្បាប់ហើយ បើដើមចោទ មិនប្តឹង មកតុលាការទេ នោះធ្វើឱ្យវឹករវរនៅក្នុងសង្គម ដូច្នេះ ត្រូវតែមានការការពារសិទ្ធិឱ្យដើមចោទ ដែលដើមចោទ

គឺជាម្ចាស់ដីកាន់កាប់ដី ដែលអាជ្ញាធរ គេទទួលស្គាល់។ ដោយឡែក ចុងចម្លើយ គាត់បានផ្ទេរសិទ្ធិដីដែលគាត់គ្មានសិទ្ធិទៅលក់ឱ្យអ្នកផ្សេង ហើយគាត់បានទៅបន្លំអាជ្ញាធរ ថាជាដីរបស់គាត់ ដូច្នេះ មានតែតុលាការទេ ដែលជាអ្នកមានសិទ្ធិសម្រេចជាសាលក្រមនៅក្នុងរឿងនេះ។ ដូចនេះ ការស្នើសុំឱ្យតុលាការសម្រេចទៅលើរឿងនេះ គឺជាការត្រឹមត្រូវ។ បើសិនជាតុលាការច្រានចោលពាក្យបណ្តឹងរបស់ដើមចោទ គឺមានន័យថា ប៉ះពាល់ភាពយុត្តិធម៌ សម្រាប់ដើមចោទ ក៏ដូចជាប៉ះពាល់ការគោរពច្បាប់នៅក្នុងសង្គម។ នេះជាចំណុចទី១ ដែលនាងខ្ញុំតបការលើកឡើងរបស់មេធាវីចុងចម្លើយ។ ចំណុចមួយទៀត អ្វីដែលចុងចម្លើយ លើកឡើងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះ ក៏ដូចជានៅក្នុងនីតិវិធីត្រៀមទាំងពីរលើកថា សំណុំរឿងនេះ មានដោះស្រាយនៅក្នុងគណៈកម្មការដោះស្រាយវិវាទដីធ្លីថ្នាក់ខេត្ត ប៉ុន្តែពិតជាគ្មានទាល់តែសោះ។ កន្លងមក គាត់និយាយ ហើយឱ្យគាត់ដាក់ភស្តុតាងមក គាត់អត់មាន ហើយនាងខ្ញុំ និងកូនក្តី មិនដែលបានទទួលលិខិតពីគណៈកម្មការដោះស្រាយវិវាទ កោះហៅក្នុងនាមទៅដោះស្រាយក្នុងនាមភាគីនោះដែរ។ មួយវិញទៀត ពាក់ព័ន្ធនឹងរឿងក្តីព្រហ្មទណ្ឌ ដែលកូនក្តីខ្ញុំប្តឹងចុងចម្លើយពីបទ គាត់លួចលក់ដីរបស់កូនក្តីខ្ញុំនេះ តុលាការបានរកឃើញថា មានបទល្មើសនោះមែន ហើយសាលាឧទ្ធរណ៍ ក៏គាត់តម្កល់សាលក្រមរបស់សាលាដំបូងខេត្តកណ្តាល ដោយសារតែមានបទល្មើស។ ទាក់ទងនឹងការបំបែកភូមិ ប្រហែលជាគាត់មិនបានពិនិត្យមើលទេ ទាក់ទងនឹងភស្តុតាងដែលនាងខ្ញុំបានដាក់ជូនតុលាការនៅក្នុងចំណុចភស្តុតាងលេខ ១១ គឺប្រកាសលេខ ៣៧៩៨ ស្តីពីការបង្កើតភូមិចំនួន ៦៣ ភូមិនៅខេត្តកណ្តាល ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ គឺឯកឧត្តម [redacted] គាត់បានចុះហត្ថលេខា ស្តីពីការបំបែកភូមិនេះ។ នាងខ្ញុំបានដាក់ជូនភស្តុតាងរួចហើយ មិនមែនចេះតែថាតែមាត់នោះទេ។

-មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ធ្វើសេចក្តីថ្លែងការណ៍តបថា ខ្ញុំស្នើសុំឱ្យ ឯកឧត្តមប្រធាន មេត្តាធ្វើការកត់សំគាល់ ដែលសហភាគាលើកឡើង ទី១ គាត់បានលើកឡើងថា ដីរបស់ភាគីទាំងសងខាង គឺមិនមានប័ណ្ណនោះទេ មានត្រឹមតែការកាន់កាប់ជាក់ស្តែង។ ការកាន់កាប់ជាក់ស្តែងនេះ កូនក្តីខ្ញុំបានកាន់កាប់ជាប់រហូតមក។ ទី២ បញ្ហាដី ដែលលោកស្រីមេធាវី បានលើកឡើងនេះ គឺកំពុងតែដោះស្រាយនៅគណៈកម្មការវិវាទដីធ្លី ទី៣ អំពីសំណុំរឿងព្រហ្មទណ្ឌដែលធ្វើការចោទប្រកាន់កូនក្តីខ្ញុំបាទ ថា បានលួចលក់អចលនវត្ថុរបស់អ្នកដទៃ នោះ គឺកំពុងដំណើរនៅតុលាការព្រហ្មទណ្ឌនៅឡើយ យើងមិនអាចសន្និដ្ឋានថា កូនក្តីខ្ញុំបានប្រព្រឹត្តនោះទេ ព្រោះមិនទាន់ មានសេចក្តីសម្រេចស្ថាពរនោះទេ។ បញ្ហាដែលវិវាទ លោកស្រីលើកអំពីទីតាំងដី គឺមិនមានភាពច្បាស់លាស់ ភាគីកូនក្តីរបស់លោកស្រី ក៏ពុំមានឯកសារបញ្ជាក់ពីម្ចាស់កម្មសិទ្ធិច្បាស់លាស់ដែរ ហេតុនេះ ហើយបានខ្ញុំស្នើសុំតុលាការពិចារណាថា ទី១ ការស្នើសុំមោឃភាពទៅលើឯកសារការផ្ទេរសិទ្ធិរបស់កូនក្តីខ្ញុំបាទនេះ គឺឃើញថា កូនក្តីលោកស្រី ក៏មានការផ្ទេរសិទ្ធិពីមួយទៅមួយ ហេតុម៉េច បានជាកូនក្តីខ្ញុំ មិនធ្វើការមោឃភាពគឺមានសិទ្ធិរៀងខ្លួន ដរាបណាគណៈកម្មការដែលមានសមត្ថកិច្ចដោះស្រាយវិវាទ រកឃើញថា អ្នកណាជាម្ចាស់កម្មសិទ្ធិពិតប្រាកដ បានយើងអាចសន្និដ្ឋានថា ឯកសារដែលកសាងឡើងមកនេះ វាខុស ផ្ទុយច្បាប់ ឬ មិនស្របច្បាប់ដោយបំពាន។ ក៏ប៉ុន្តែពេលនេះការដោះស្រាយមិនទាន់ចេញ អាជ្ញាធរស្រុក នៅតែអះអាងថាជាហត្ថលេខារបស់គាត់ ហើយទទួលស្គាល់ថា ដីរបស់ឈ្មោះ [redacted] សុវណ្ណ លក់ឱ្យអ្នកទិញ ០៧ នាក់ទៀត។ កូនក្តីខ្ញុំ នៅតែទទួលស្គាល់ថា គាត់បានលក់ដីនោះ ភាគីម្ខាងទៀត មិនទាន់មានឯកសារអ្វី ៗ

បញ្ជាក់មកស្នើសុំ។ ការស្នើសុំមោឃភាពនេះ វាមិនស្របនឹងច្បាប់ វាមិនស្របជាមួយនឹងសិទ្ធិ ដែលខ្លួនមាន។ ចំពោះពាក់ព័ន្ធនឹងគណៈកម្មការសុរិយោដី ខ្ញុំសុំឱ្យកូនក្ដីខ្ញុំគាត់បំភ្លឺ។

-ចុងចម្លើយឈ្មោះ [redacted] សុវណ្ណ បានអះអាងថា ៖ ពាក្យបណ្ដឹង ខ្ញុំបានដាក់ចូលសាលាខេត្ត ប៉ុន្តែពេលនេះ ខ្ញុំនៅទីនេះ មិនអាចទៅយកបាន។ ខ្ញុំនឹងឱ្យលោកមេធាវីគាត់ទៅរកពាក្យបណ្ដឹងនោះ ដោយសារពេលដាក់ប្ដឹងនោះ ខ្ញុំប្ដឹងឈ្មោះ តាន់ ជូវហុង និងលោកស្រី [redacted] ជានី។

-មេធាវី [redacted] ថ្លែងការណ៍ថា ខ្ញុំនៅតែស្នើសុំ តុលាការពិចារណាអំពីបណ្ដឹងនេះឱ្យបានច្បាស់សិន បើសិនជាតុលាការធ្វើសេចក្ដីសម្រេចថា តុលាការទទួលបណ្ដឹងនេះ ដោយច្រានចោលការស្នើសុំឱ្យលើកបណ្ដឹងចោលរបស់ខ្ញុំបាទ ហើយបន្តនីតិវិធី ពេលនោះខ្ញុំបាទនឹងរៀបចំឯកសារបន្តនីតិវិធីតាមផ្លូវច្បាប់។

-មេធាវី [redacted] ថ្លែងការណ៍ថា ខ្ញុំសុំប្រកាន់សេចក្ដីថ្លែងការណ៍ ដដែល ដោយទី១ បណ្ដឹងនេះជាបណ្ដឹងមិនស្របច្បាប់ដោយស្នើសុំឱ្យតុលាការលើកចោលពាក្យបណ្ដឹង ដោយហេតុថា បណ្ដឹងនេះជាវិវាទពាក់ព័ន្ធនឹងកម្មសិទ្ធិដី ដោយភាគីទាំងពីរ មិនទាន់មានឯកសារកម្មសិទ្ធិច្បាស់លាស់នៅលើទីតាំងដីនេះពិតប្រាកដនៅឡើយទេ គឺភាគីមិនទាន់មានឯកសារច្បាស់លាស់នៅឡើយ។ នៅក្នុងនោះ ពាក្យបណ្ដឹងរបស់ដើមចោទ ស្នើសុំមោឃភាពឯកសារទិញលក់រវាងកូនក្ដីខ្ញុំបាទ [redacted] សុវណ្ណ ជាមួយនឹង តតិយជន ដែលឯកសារទាំងនោះមានការទទួលស្គាល់ និងចុះហត្ថលេខាដោយអាជ្ញាធរភូមិឃុំ និងស្រុក រួចទៅហើយ។ ដូច្នេះ ឯកសារនេះ ជាឯកសារធ្វើឡើងរវាងភាគីឯកជន ហើយធ្វើឡើងដោយមិនមានបញ្ញត្តិមួយណា ដែលថា ធ្វើឡើងផ្ទុយនឹងច្បាប់នោះទេ។ ការទិញលក់នេះ គឺទៅលើកម្មវត្ថុទិញលក់ដី ដែលជាសិទ្ធិរបស់កូនក្ដីខ្ញុំឈ្មោះ [redacted] សុវណ្ណ។ ហេតុនេះ ការបង្ហាញឆន្ទៈទៅលើ ការទិញលក់របស់គាត់ដែលមិនបំពានទៅលើក្រមរដ្ឋប្បវេណី ដូចមានចែងនៅក្នុងមាត្រា ៣៥៧ ជាដើមនេះ។ ដូច្នេះការទិញលក់របស់គាត់ស្របច្បាប់ ហើយភាគីតតិយជនស្នើសុំមោឃភាព ហើយការមោឃភាពនេះ គឺជាចំណុចដែលខ្ញុំបាទយល់ឃើញថា មិនស្របទៅនឹងបញ្ញត្តិច្បាប់ ដែលអនុញ្ញាតឱ្យភាគីស្នើសុំមោឃភាព។ ទី២ នៅក្នុងកម្មវត្ថុ នៃបណ្ដឹងស្នើសុំបន្ថែមនូវកម្មវត្ថុបណ្ដឹង គឺស្នើសុំ ឱ្យទទួលស្គាល់ដីដែលមានទំហំ ៥៥៧២១២ ម៉ែត្រការ៉េ ស្នើសុំឱ្យតុលាការទទួលស្គាល់។ ដីរបស់ខ្លួន កម្មសិទ្ធិរបស់ខ្លួន ទាមទារជាម្ចាស់កម្មសិទ្ធិ ក៏ប៉ុន្តែស្នើសុំឱ្យតុលាការទទួលស្គាល់ ហើយឯកសាររបស់ខ្លួន អត់មានអ្វីក្រៅពីការទិញលក់ជាមួយប្រជាពលរដ្ឋ ហើយទំហំនៃការទិញលក់ គឺប្រៀបធៀបអំពីទំនាក់ទំនងសិទ្ធិ និងគតិយុត្តិ កូនក្ដីខ្ញុំមានឯកសារទទួលស្គាល់ដោយអាជ្ញាធរស្រុក ហើយភាគីស្នើសុំឱ្យតុលាការទទួលស្គាល់ដីរបស់ខ្លួនត្រឹមតែ ឯកសារទិញលក់ឯកជនតែប៉ុណ្ណោះ។ កម្មវត្ថុទី២ ស្នើសុំឱ្យបង្គាប់ឱ្យមន្ទីរសុរិយោដី ធ្វើការចុះបញ្ជីដីទំហំ ៥៥៧២១២ ម៉ែត្រការ៉េ ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ជានី។ ដូច្នេះ ការស្នើសុំ ទី១ ឱ្យតុលាការទទួលស្គាល់សិទ្ធិរបស់ខ្លួន ដែលសិទ្ធិរបស់ខ្លួននៅមិនទាន់ច្បាស់លាស់នៅឡើយទេ ទី២ ស្នើសុំឱ្យតុលាការ បង្គាប់ទៅមន្ទីរសុរិយោដី ដែលមន្ទីរសុរិយោដីនេះ គឺមិនមែនជាគូភាគីទេ ចុះបើមន្ត្រីសុរិយោដី មិនព្រមចុះបញ្ជីឱ្យ មានសិទ្ធិឯណាទៅបញ្ជាឱ្យចុះបញ្ជីឱ្យ។ បទបញ្ញត្តិនេះ គឺមិនស្របទៅនឹងក្រម ដូច្នេះ ខ្ញុំឃើញថា ការស្នើសុំនៅក្នុងបណ្ដឹងនេះ មិនស្របច្បាប់ ខ្ញុំនៅតែទទូចស្នើសុំឱ្យ ឯកឧត្ដមប្រធាន ពិចារណាលើកបណ្ដឹងនេះចោល ព្រោះបណ្ដឹងនេះ ផ្ទុយនឹងច្បាប់។ទី២ បណ្ដឹងនេះ មិនមែនជាសមត្ថកិច្ចរបស់តុលាការ មានន័យថា តុលាការអសមត្ថកិច្ចអំពីវិវាទដីធ្លីដែលមិនទាន់ចុះបញ្ជី។ តាមប្រកាសអន្តរក្រសួង



Scanned with CamScanner

ស្ដីអំពីបង្កើតគណៈកម្មការសុរិយោដី គឺមានន័យថា បង្កើតគណៈកម្មការសុរិយោដី ទាំងថ្នាក់ស្រុក និងថ្នាក់ខេត្ត រហូតដល់ថ្នាក់ជាតិ ដើម្បីដោះស្រាយលើវិវាទដីធ្លីដែលមិនទាន់ចុះបញ្ជី។ ដូច្នេះ ចំណុចទាំងអស់នេះ ខ្ញុំយល់ឃើញថា គណៈកម្មការសុរិយោដី កំពុងតែដោះស្រាយបន្តនីតិវិធី ដូចដែលខ្ញុំបានថ្លែងលើកមុន ហើយឯកឧត្តមប្រធាន បានឱ្យខ្ញុំបាទទៅរកឯកសារនោះ ហើយខ្ញុំបាទព្យាយាមទៅរកឯកសារនោះ ប៉ុន្តែកូនក្ដីខ្ញុំ នៅពន្ធនាគារ ហើយទី២ តាំងពីពេលនោះមក មន្ត្រីសាលាខេត្តគាត់មានការជាប់រវល់ ហើយខ្ញុំបាទព្យាយាម រកឯកសារបង្ហាញនៅក្នុងសំណុំរឿងនេះ ត្រូវបានដំណើរការ និងកំពុងដំណើរការនៅគណៈកម្មការសុរិយោដី នៅឡើយ ខ្ញុំនឹងស្នើសុំបញ្ជូននៅពេលក្រោយរួមទាំង សេចក្ដីថ្លែងការណ៍។ ខ្ញុំបានទំនាក់ទំនងកូនក្ដីខ្ញុំ តាមរយៈទូរស័ព្ទ ដើម្បីឱ្យគាត់ទៅរក ប៉ុន្តែនៅក្នុងដំណាក់កាលនេះ មិនអាចទំនាក់ទំនងតាមទូរស័ព្ទបាន។ ខ្ញុំបានព្យាយាមទៅស្វែងរកចំនួនពីរដង ទំនាក់ទំនងទៅមន្ត្រីអន្តរវិស័យដោះស្រាយទំនាស់ដីធ្លី ប៉ុន្តែមិនបានជួប ខ្ញុំបាទស្នើសុំឯកឧត្តមប្រធាន ទុកពេលឱ្យខ្ញុំបាទ ដាក់នូវឯកសារភស្តុតាងតាមក្រោយ។ នៅក្នុងចំណុចទាំងអស់នេះ ខ្ញុំបាទជម្រាបជូនថា ខ្ញុំបាទស្ថិតនៅក្នុងមេធាវីស្ម័គ្រចិត្តរបស់សម្ដេចតេជោ កំពុងតែមានបញ្ហាដោះស្រាយប្រហាក់ប្រហែលគ្នានេះ ដោយភាគីគូវិវាទប្ដឹងផ្ដល់គ្នា ក៏ប៉ុន្តែនៅពេលដែលតុលាការសម្រេចក៏អនុវត្តទៅលើតតិយជន នេះខ្ញុំចង់បង្ហាញថា យកតុលាការធ្វើជាឈ្នាន់ ដើម្បីអំពើទុច្ចរិតរបស់ខ្លួន ដើម្បីអនុវត្តទៅបាន ហើយករណីនេះ កំពុងដោះស្រាយនៅ៣ខេត្ត គឺមានខេត្តតាកែវ និងខេត្តពីរទៀតកំពុងតែដោះស្រាយ ហើយការស្រាវជ្រាវរកទៅឃើញថា តតិយជនស្លូតត្រង់នោះ។ ដូច្នេះហើយ ខ្ញុំបាទស្នើសុំឱ្យឯកឧត្តមប្រធាន មេត្តាពិចារណាលើកបណ្ដឹងនេះចោល។ អំពីចំណុចដែលខ្ញុំត្រូវធ្វើការឆ្លើយតប ខ្ញុំសូមបង្ហាញថា ឯកសារទិញលក់ដីធ្លីនេះ មាននៅក្នុងសំណុំរឿងរួចហើយ ឃើញថា កូនក្ដីខ្ញុំបាទបានកាន់កាប់ដីតាំងពីឆ្នាំជាង៤០ ដោយសារគាត់ជាទ័ពនៅទីនោះ។ នៅក្នុងឆ្នាំ២០១៦ គាត់ត្រូវបានផ្ទេរឯកសារទិញលក់នោះ ចូលទៅតតិយជន ដោយលោក បានកាន់កាប់ដីនៅក្នុងតំបន់នោះជារៀងរហូតមក ក៏ប៉ុន្តែវិវាទភាគីដើមបណ្ដឹងបានប្ដឹងមោឃភាព។ មូលហេតុ ភាគីដើមបណ្ដឹងចោទ ភាគីកូនក្ដីខ្ញុំបាទ ថា លួចលក់អចលនវត្ថុអ្នកដទៃ។ទី១ គាត់កំពុងតែធ្វើការចោទប្រកាន់ថាកូនក្ដីខ្ញុំបាទ លួចលក់អចលនវត្ថុរបស់គាត់ ទី២ គាត់កំពុងតែយកដៃតុលាការមកបង្ហាញថា ស្នើសុំឱ្យតុលាការទទួលស្គាល់ថា ដីនេះជាដីរបស់គាត់ ដើម្បីធ្វើជាកម្មសិទ្ធិរបស់គាត់។ សួរថាតើគាត់មានកម្មសិទ្ធិដីធ្លីច្បាស់លាស់ដែលទទួលស្គាល់ដោយអាជ្ញាធរហើយឬនៅ? មិនទាន់។ ទោះបីជារឿងនេះ ស្ថិតនៅក្នុងសារណានៃការការពារនេះ តែវាក៏បង្ហាញអំពីសិទ្ធិនៃការកាន់កាប់ដីធ្លី របស់កូនក្ដីខ្ញុំបាទនៅក្នុងទីតាំងដីដែលមានវិវាទនេះ ហើយខ្ញុំបាទ ស្នើសុំបញ្ចូលឯកសារនេះជាមួយនឹងឯកសារដែលខ្ញុំបាទស្នើសុំឯកឧត្តមប្រធាន បញ្ចូលនៅពេលក្រោយ។ ខ្ញុំនៅតែទទូចស្នើសុំពិចារណានូវចំណុចដែលខ្ញុំបាទបានលើកឡើងនេះ។

-មេធាវី [redacted] ថ្លែងការណ៍ថា ទាក់ទងនឹងការលើកឡើងរបស់មេធាវី ពាក់ព័ន្ធដែលថាបណ្ដឹងនេះជាបណ្ដឹងមិនស្របច្បាប់ តាមមាត្រា ៣៥៧ នោះ គឺ ឃើញថា នៅក្នុងមាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណី បានចែងរួចហើយថា " ប្រសិនបើអត្ថន័យនៃសកម្មភាព ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀបទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន។" ដូច្នេះ មានន័យថា មិនមែនមានតែភាគីទេ តតិយជនក៏មានសិទ្ធិក្នុងការប្ដឹងសុំមោឃភាពបានដែរ។ ទាក់ទងនឹងថា ការជំនុំជម្រះក្ដី ដែលថា តុលាការអសមត្ថកិច្ចនោះ នាងខ្ញុំស្នើសុំឱ្យគាត់ពិនិត្យ

មើលមាត្រា ១៤ នៅក្នុងនីតិវិធីរដ្ឋប្បវេណី ដែលបានបញ្ជាក់ សមត្ថកិច្ចសាលាជម្រះក្តីដែលបានកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ ចែងថា "នៅពេលដែលចុងចម្លើយបានធ្វើសេចក្តីដោះសារអំពីអង្គសេចក្តីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬបានឆ្លើយទាញហេតុផលអំពីអង្គសេចក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ នៅតុលាការនៃការជំនុំជម្រះលើកទី១ ដោយគ្មានការតវ៉ាអំពីកំហុសនៃសមត្ថកិច្ចសាលាជម្រះក្តីនោះ តុលាការនេះ ត្រូវមានសមត្ថកិច្ចជម្រះក្តី។" កន្លងមក នៅក្នុងនីតិវិធីត្រៀមលើកទី១ គឺលោកមេធាវី គាត់មិនបានចូលរួមនោះទេ ហើយនីតិវិធីត្រៀមលើកទី២ គាត់ បានលើកឡើង ប៉ុន្តែគាត់មិនបានធ្វើពាក្យសុំជាលាយលក្ខណ៍អក្សរនោះទេ គឺមានតែការថ្លែងការណ៍នៅក្នុងកំណត់ហេតុ។ ដូច្នេះ ការបន្តនីតិវិធីរបស់តុលាការ នាងខ្ញុំយល់ឃើញថា គឺមិនខុសនីតិវិធីច្បាប់នោះទេ ហើយចំណុចមួយទៀត ការលើកឡើងនូវឯកសាររបស់គាត់ ឃើញថា គាត់បានលើកឡើងនៅក្នុងនីតិវិធីត្រៀមលើកទី២ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ បើគិតរយៈពេលដែលលោកស្នើសុំលោកចៅក្រមដើម្បីទៅរកឯកសារនៅសាលាខេត្ត ពាក់ព័ន្ធនឹងរឿងដីនេះ ដែលបញ្ជាក់ថា កំពុងដំណើរការនៅសាលាខេត្តនោះ ឃើញថា មកដល់ខែកញ្ញា នេះ ក៏លោកមិនបានដាក់ឯកសារមកតុលាការនោះទេ ដោយលោកតែងតែពន្យារពេលម្តងជាពីរដងរហូតដល់លើកនេះទៀត គឺលើកទី៣ហើយ ដូច្នេះ នាងខ្ញុំស្នើសុំឱ្យលោកប្រធានពិចារណា។ ចំពោះចំណុចដែលគាត់បានលើកឡើងថា ឯកសារទិញលក់ដីរបស់កូនក្តីរបស់គាត់ គឺជាឯកសារមានការទទួលស្គាល់ពីអាជ្ញាធរ ប៉ុន្តែនាងខ្ញុំ និងសហភាតារបស់នាងខ្ញុំ ក៏បានដាក់បញ្ចូលនូវលិខិតបដិសេធរបស់អាជ្ញាធរមូលដ្ឋាន អំពីការលក់ទិញដីនោះ ដោយមូលហេតុអ្វីបានជាគាត់ធ្វើការចុះហត្ថលេខាលើឯកសារនោះ ហើយមូលហេតុអ្វីដែលគាត់ធ្វើការបដិសេធលើលិខិតនោះវិញ។ ដូចនេះ ក្នុងចំណុចទាំងអស់នេះ គឺមានការបដិសេធនូវការចុះហត្ថលេខានូវការទិញលក់ ទើបមានការប្តឹងតគ្នាដើម្បីស្វែងរកការបញ្ជាក់ថាតើអ្វីដែលគាត់យកដីគេទៅលក់នោះ ត្រឹមត្រូវតាមច្បាប់ឬទេ។ ការប្តឹងសុំមកតុលាការនោះ គឺដើម្បីបញ្ជាក់ថា ឯកសារទិញលក់គាត់ត្រឹមត្រូវ ឬមិនត្រឹមត្រូវ បើមិនត្រឹមត្រូវ គឺកូនក្តីខ្ញុំមានសិទ្ធិក្នុងការប្តឹងមោឃភាពនោះ ហើយមាត្រាច្បាប់ក៏មិនមានការហាមឃាត់ មិនឱ្យកូនក្តីខ្ញុំប្តឹងមោឃភាពដែរ។ នាងខ្ញុំស្នើសុំឯកឧត្តមប្រធាន ពិនិត្យពិចារណាលើចំណុចទាំងអស់នោះដែរ។

-មេធាវី [redacted] ថ្លែងការណ៍ថា ខ្ញុំសំណូមពរឯកឧត្តមប្រធាន បញ្ចប់ការដាក់ភស្តុតាងនៅក្នុងថ្ងៃនេះ ដើម្បីកុំឱ្យមានការអូសបន្លាយពេលវេលាតទៅទៀត ដោយការលើកឡើងរបស់ចុងចម្លើយ គ្រាន់តែជាលេសប៉ុណ្ណោះ ហើយសូម្បីចំណុចដែលគាត់ថា គាត់ទិញលក់ដីបន្តពីបីនាក់នោះ គឺមិនមានឯកសារនោះទេ។

-មេធាវី [redacted] ថ្លែងការណ៍ថា ចំណុចដែលខ្ញុំលើកឡើងថា តុលាការអសមត្ថកិច្ច នោះ គឺយោងតាមប្រកាសអន្តរក្រសួង ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣។ វិវាទដីធ្លី ដែលយើងកំពុងដំណើរការនេះ គឺមិនមានឯកសារទទួលស្គាល់ពីសុរិយោដី ឡើយ។ អំពីចំណុចស្នើសុំមោឃភាព គឺស្ថិតនៅក្នុងចំណុចបញ្ញត្តិនៃច្បាប់ដែលអាចឱ្យយើងឃើញទាំងអស់គ្នាថា វាកំពុងតែស្ថិតនៅ ថាតើការទិញលក់នេះ វាស្រប ឬមិនស្រប ទៅនឹងច្បាប់ ធៀបនឹងឯកសាររបស់កូនក្តីខ្ញុំបាទ វាមិនស្របទៅនឹងបញ្ញត្តិច្បាប់ ដែលអនុញ្ញាតឱ្យមានការមោឃភាព ស្របទៅតាមមាត្រា ៣៥៧ នេះ គឺលុះត្រាតែ កិច្ចសន្យានោះធ្វើឡើងដែលផ្ទុយនឹង បញ្ញត្តិនៃការអនុវត្តដោយបង្ខំ ធ្វើឡើងផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ហើយកិច្ចសន្យាទិញលក់ មានអ្វីដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ផ្ទុយនឹងការអនុវត្តដោយបង្ខំ បើមិនទាន់ដឹងថា ម្ចាស់

កម្មសិទ្ធិដីធ្លីនោះ គឺជាអ្នកណាផង។ បើយោងតាម ទំហំ និងទំនាក់ទំនងគតិយុត្តិនៃកិច្ចសន្យារបស់កូនក្តីខ្ញុំ គឺត្រូវបានមានទំហំធ្ងន់ជាងភាគីម្ខាងទៀត។ ចំណុចដែលស្នើសុំ មិនអនុញ្ញាតឱ្យយើងខ្ញុំពន្យារពេលដាក់ឯកសារជាភស្តុតាង ក៏ដូចជាសេចក្តីថ្លែងការណ៍ គឺមាននៅក្នុងមាត្រា ១០៨ ឃើញច្បាស់ហើយ។ ករណីនេះ ខ្ញុំចង់និយាយថា ការដាក់មធ្យោបាយ និងភស្តុតាងនេះ គឺមិនមានភាពយឺតយ៉ាវទេ ដែលតុលាការមិនអាចទទួលយកបានទេ បញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ គឺពេលប្រកាសសាលក្រម នៅក្នុងអំឡុងពេល មិនទាន់បានប្រកាសសាលក្រមនោះទេ គឺវាស្ថិតនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ ដូច្នេះ មិនមានការយឺតយ៉ាវក្នុងការដាក់ភស្តុតាង ដែលមិនអាចទទួលយកបាននោះទេ។ ខ្ញុំសុំបញ្ចូលភស្តុតាងនេះ ដោយសារភស្តុតាងនេះ ជាភស្តុតាងពិបាករក ដោយសារត្រូវទំនាក់ទំនងជាមួយ និងមន្ត្រីដែលជាអ្នកកាន់ឯកសារនោះ។

## ៤. ចំណុចខុសខាត

១. តើការប្តឹងសុំមោឃភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ចំនួន ០៧ច្បាប់ របស់សហដើមចោទ មានលក្ខណៈត្រឹមត្រូវដែរឬទេ?

២. តើការសុំបន្ថែមកម្មវត្ថុនៃបណ្តឹង របស់ដើមចោទ មានលក្ខណៈត្រឹមត្រូវដែរឬទេ?

### សំអាងហេតុ

*តាមលទ្ធផលនៃការសាកសួរសោមីភាគី*

*និងពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖*

១- តាមសេចក្តីថ្លែងការណ៍របស់មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ថា ការស្នើសុំមោឃភាពចោលលិខិតផ្ទេរសិទ្ធិទាំងនេះ ព្រោះដោយហេតុថា ទី១ ឈ្មោះ [redacted] សុវណ្ណ គាត់មិនមានដីស្ថិតនៅលើដីដែលគាត់បានផ្ទេរសិទ្ធិទៅឱ្យអ្នកទាំង០៧ នាក់នោះទេ ទី២ ដីទំហំ ១២៥ ហិចតានេះ គឺឈ្មោះ [redacted] សុវណ្ណ គាត់ផ្ទេរសិទ្ធិទៅឱ្យឈ្មោះ [redacted] ម៉េងឡុង ទំហំ ១២៥ហិចតា ហើយគាត់បានផ្ទេរសិទ្ធិឱ្យអ្នកទាំង០៦នាក់ទៀត នោះពុះជាចំណែកតូចៗ នៅលើទំហំដី ១២៥ហិចតា ដែលគាត់ផ្ទេរជាន់គ្នាដដែល។ ទាក់ទងនឹងឯកសារដែលនាងខ្ញុំស្នើសុំផ្ទេរសិទ្ធិនេះ យើងមានភស្តុតាង ដែលដាក់ជូននៅក្នុងនីតិវិធីត្រៀមរួចហើយ នាងខ្ញុំស្នើសុំឯកឧត្តមប្រធាន មេត្តាពិនិត្យភស្តុតាងដែល នាងខ្ញុំបានដាក់ជូននេះ។ យើងមានលិខិតបដិសេធជាផ្លូវការរបស់លោកមេឃុំ [redacted] គង់ ជាមេឃុំ បន្ទាយដែក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ ដែលគាត់បានបញ្ជាក់អំពីឈ្មោះ[redacted]សុវណ្ណ ដែលជាចុងចម្លើយនេះ គាត់មានចេតនាបង្ខំគាត់ ដើម្បីយកដីដដែលទៅឱ្យគាត់ផ្ទេរសិទ្ធិជាន់គ្នា។ ទីតាំងដីរបស់ ដើមចោទឈ្មោះ [redacted] ជួរហុង គឺស្ថិតនៅក្នុងភូមិខ្សុំ (បច្ចុប្បន្នអង្គរជ័យ)។ លោក [redacted] ជួរហុង គាត់បានដាក់លិខិតផ្ទេរសិទ្ធិដីធ្លី ចំនួន ១៩ ហិចតា ដែលគាត់បានទិញពីប្រជាពលរដ្ឋ ដោយមានភូមិឃុំទទួលស្គាល់ដឹងឮត្រឹមត្រូវ ដែលលិខិតទាំងនេះ បានដាក់ជូនជាភស្តុតាងជូនតុលាការរួចហើយ។ ដីដែលឈ្មោះ [redacted] សុវណ្ណ គាត់ធ្វើលិខិតប្រគល់លក់ជាន់គ្នា ១២៥ ហិចតានេះ គាត់ដាក់ទីតាំងដែលគាត់លក់នោះ នៅភូមិកណ្តាលលើ ប៉ុន្តែនៅពេលដែលវាស់យកដី គឺវាស់យកដីនៅភូមិអង្គរជ័យ ដែលដីនេះកាន់កាប់គ្រប់គ្រង ដោយដើមចោទតាំងពីឆ្នាំ២០១០ រហូតដល់បច្ចុប្បន្ននេះ ក៏ដើមចោទនៅតែគ្រប់គ្រងនេះ។ ទីតាំងដីពិតប្រាកដ ដែលទំនាស់គ្នា ទំហំ ១២៥ ហិចតា នេះ ជាដីរបស់ឈ្មោះ [redacted] ជួរហុង ស្ថិតនៅភូមិអង្គរជ័យ (អតីតភូមិខ្សុំ)។ ដីដែលឈ្មោះ [redacted] សុវណ្ណ គាត់វាស់លក់ឱ្យគេនោះ គឺគាត់វាស់ចូលទៅ ៗ

ដីរបស់ឈ្មោះ [redacted]ជូរហុង ប្រហែល ៦ ទៅ ៧ ហិចតា និងចូលដីរបស់ឈ្មោះ [redacted] ផានី ប្រហែល ៥០ ហិចតា។

២. តាមសេចក្តីថ្លែងការណ៍របស់មេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា ទាក់ទងនឹងការចុះទៅវាស់ដី ដែលមានអាជ្ញាធរចូលរួម ដែលមានអក្សរអាប់ស៊ីស និងអរដោណេ រួចហើយ ដែលនាងខ្ញុំបានដាក់ជូនភស្តុតាងរួចហើយ នៅក្នុងសំណុំរឿងនេះ។ នៅក្នុងដីរបស់ឈ្មោះ [redacted] ផានី នេះ គឺទំហំដី ៥៥ ហិចតា ៧២ អា ដែលគាត់បានធ្វើការវាស់វែងដោយមានការចូលរួមពីអាជ្ញាធរខេត្ត លើទំហំដី និងទីតាំងដីនេះ។

៣. តាមសេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] សុវណ្ណ ថា ៖ ដីរបស់ខ្លួនសរុបទំហំ ១២៥ ហិចតា ស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ។ ដីរបស់ខ្លួន មានអាជ្ញាធរភូមិឃុំ និងស្រុកទទួលស្គាល់ មានឯកសារត្រឹមត្រូវ។ លោកអភិបាល គាត់បានឱ្យមន្ត្រីសុរិយោដីខេត្ត ចុះទៅពិនិត្យជាមួយលោកអភិបាលរងមួយទៀត និងសុរិយោដីស្រុក ចុះទៅដល់ទីតាំងដី ហើយលោកក៏បានឯកភាព ការកាយដីនេះ គឺត្រូតលើគ្នា។ លោកស្រី [redacted] ផានី និងលោក [redacted] ជូរហុង នេះ គាត់ទើបតែទៅកាយដីនៅឆ្នាំ ២០១៩ ខែ០៥ នេះទេ គាត់គ្មានឯកសារអ្វីទាំងអស់ ហើយដីខ្លួននេះ គឺកំពុងតែដោះស្រាយគ្នានៅគណៈកម្មការខេត្ត ដោយមានឯកឧត្តម [redacted] សោភ័ណ្ឌ ជាអ្នកដោះស្រាយ ព្រោះខ្លួនបានប្តឹងមិនឱ្យចុះបញ្ជីធ្វើប្លង់។ ខ្លួនក៏បានប្តឹងទៅដល់ក្រសួងទៀត ដូច្នេះ រឿងនេះ ខ្លួនកំពុងតែដោះស្រាយនៅគណៈកម្មការខេត្តបច្ចុប្បន្ននេះ។ ខ្លួនមានឯកសារត្រឹមត្រូវ។ ដីរបស់ខ្លួនស្ថិតនៅភូមិកណ្តាលលើ ចំណែកដីរបស់ឈ្មោះ[redacted]ជូរហុង ស្ថិតនៅភូមិខ្សុំ។ បច្ចុប្បន្ន គេមិនមានបំបែកភូមិអ្វីនោះទេ បើសិនជាគាត់ថាមានការបំបែកភូមិ ខ្លួនស្នើសុំលិខិតស្នាមបំបែកភូមិ ដែលអាជ្ញាធរដឹងឮ។ ដីរបស់ខ្លួន នៅភូមិកណ្តាលលើ ដីរបស់ឈ្មោះ [redacted] ជូរហុង នៅភូមិខ្សុំ និងដីរបស់ឈ្មោះ [redacted] ផានី នៅភូមិកណ្តាលលើដែរ។ គាត់ចេះតែចោទប្រកាន់ខ្លួន។ ភូមិទាំងពីរនេះ គឺនៅជាប់គ្នា ហេតុនេះហើយ បានជាខ្លួនប្តឹងដល់ខេត្ត។ ដីរបស់ខ្លួន មានអាជ្ញាធរភូមិឃុំស្រុកទទួលស្គាល់ដឹងឮ។ ខ្លួននឹងដាក់ឯកសារជូនតុលាការ។ ដីទំហំ ១២៥ ហិចតា នេះ ខ្លួនបានសុំរដ្ឋកាន់កាប់តាំងពីឆ្នាំ១៩៩៨ ខ្លួនបានចូលកាន់កាប់តាំងពីមុនគេបំផុត។

៤. តាមសេចក្តីថ្លែងការណ៍របស់មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយថា ខ្លួនស្នើសុំឱ្យតុលាការធ្វើការកែតម្រូវលើពាក្យបណ្តឹងទាំងនេះ ដោយមូលហេតុថា ពាក្យបណ្តឹងនេះជាពាក្យបណ្តឹងផ្ទុយច្បាប់ មានន័យថា មិនមានចំណុចមួយណា ដែលអនុញ្ញាតឱ្យភាគីស្នើសុំ មោឃភាពទៅលើឯកសាររបស់អាជ្ញាធរ ដែលធ្វើឡើងដោយអាជ្ញាធរ នោះទេ។ ទី២ ឯកសារទាំងនេះ គឺជាឯកសារដែលធ្វើឡើងរវាងកូនក្តីខ្លួន និងជាមួយភាគីអ្នកទិញ ដោយធ្វើឡើងដោយឯកជន និងឯកជន មានការទទួលស្គាល់ដោយសមត្ថកិច្ច។ សំណុំរឿងរដ្ឋប្បវេណីអនុវត្តទៅបាន លុះត្រាតែសិទ្ធិរបស់អ្នកនោះ មាននៅក្នុងច្បាប់ ចែងនៅក្នុងក្រមរដ្ឋប្បវេណី ប៉ុន្តែការស្នើសុំមោឃភាពនេះ មិនមានចែងអំពីសិទ្ធិនេះ នៅក្នុងក្រមរដ្ឋប្បវេណីទេ។ ដូច្នេះ នៅក្នុងនីតិវិធីត្រៀមលើកទី១ លើកទី២ ខ្លួននៅតែព្យាយាមស្នើសុំឱ្យតុលាការធ្វើការកែតម្រូវ ឬ ក៏លើកចោលពាក្យបណ្តឹងនេះ ដោយសារមូលហេតុ ពាក្យបណ្តឹងផ្ទុយច្បាប់។ នេះជាចំណុចដែលខ្លួនស្នើសុំ ឯកឧត្តមប្រធាន មេត្តា ពិចារណា ឱ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ ដោយសារភាគីតាមការយល់របស់ខ្លួន ភាគីវិវាទអំពីកម្មសិទ្ធិនៅលើដី ប៉ុន្តែកូនក្តីខ្លួនបានលើកឡើងអំបាញ់មិញនេះ សិទ្ធិទាំងអស់នេះត្រូវបានកំពុងដោះស្រាយនូវវិវាទនៅគណៈកម្មការដោះស្រាយវិវាទដីធ្លី។ ទី២ សំណុំ ០៨៥



Scanned with CamScanner

រឿងនេះ ត្រូវបានភាគីដើមចោទ ធ្វើការចោទកូនក្ដីខ្លួន ថាកាន់កាប់អចលនវត្ថុអ្នកដទៃ ហើយកំពុងដំណើរការ សំណុំរឿងនេះ នៅតុលាការព្រហ្មទណ្ឌ មិនទាន់បានចប់។ ស្រាប់តែមានការស្នើសុំមោឃភាពទៅលើឯកសារផ្ទេរសិទ្ធិរបស់កូនក្ដីខ្លួននេះ។ ខ្លួនសំណូមពរ សុំឱ្យឯកឧត្តមប្រធាន ពិចារណា ថាតើបណ្ដឹងនេះស្របច្បាប់ ឬ មិនទាន់ស្របច្បាប់? ខ្លួនឃើញថា នៅក្នុងកំណត់ហេតុនៅក្នុងនីតិវិធីត្រៀម ត្រង់ចំណុចវិវាទគឺ ចំណុចទី១ តើការស្នើសុំមោឃភាព លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ចំនួន ០៧ ច្បាប់របស់ដើមចោទមានលក្ខណៈត្រឹមត្រូវ ដែរ ឬទេ? ថាតើឯកសារនេះ ត្រឹមត្រូវ ឬទេ ដូច្នេះ មិនទាន់ត្រូវលើកអំពីសិទ្ធិ អ្នកណាកាន់កាប់ ឬអ្នកណាមានសិទ្ធិ ដែលត្រូវលើកមកបង្ហាញតុលាការនាពេលនេះទេ។ ខ្លួនស្នើសុំ ឯកឧត្តមប្រធាន មេត្តាពិចារណា ថា តើពាក្យបណ្ដឹងស្របច្បាប់ ដែលគួរតុលាការ លើកយកមកពិចារណា ដែរឬទេ? ប្រសិនជា ឯកឧត្តមប្រធាន យល់ឃើញថា ជាការស្របច្បាប់ ខ្លួនស្នើសុំឯកឧត្តមប្រធាន បន្តនីតិវិធីនៅពេលក្រោយ ឬ នៅពេលណា ទៅតាមការសម្រេចរបស់ ឯកឧត្តមប្រធាន បើមិនស្របច្បាប់ទេ ខ្លួនស្នើសុំឱ្យ ឯកឧត្តមប្រធាន លើកបណ្ដឹងនោះចោល។ ប្រសិនបើ ឯកឧត្តមប្រធាន លើកយករឿងនេះបន្ត ខ្លួនមិនមានអ្វីស្នើសុំបន្ថែមទេ ដោយហេតុថា បណ្ដឹងនេះ វាស្ថិតនៅក្នុងបណ្ដឹងផ្ទុយច្បាប់ ខ្លួនរក្សាសិទ្ធិក្នុងការការពារ ការយល់ឃើញរបស់ខ្លួន។

៥. តាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានលើកឡើងចាប់តាំងពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល រហូតដល់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះ ថា បណ្ដឹងផ្ទុយច្បាប់ ប៉ុន្តែមិនបានលើកឡើងពីលក្ខខណ្ឌនៃភាពផ្ទុយច្បាប់មកបញ្ជាក់ជូនតុលាការនោះទេ។ លើសពីនេះទៀត ចុងចម្លើយ និងមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានលើកឡើងថា វិវាទនេះកំពុងដោះស្រាយនៅគណៈកម្មការសុរិយោដី ប៉ុន្តែចាប់តាំងពីដំណើរការនីតិវិធី រហូតមកដល់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ គឺចុងចម្លើយពុំបានដាក់ឯកសារជាភស្តុតាងដើម្បីបញ្ជាក់ជូនតុលាការថា វិវាទដីធ្លីរបស់ខ្លួន និងសហដើមចោទគឺពិតជាមានពាក្យបណ្ដឹង និងដំណើរការដោះស្រាយនៅចំពោះមុខគណៈកម្មការដោះស្រាយវិវាទដីធ្លីនៅសាលាខេត្តកណ្ដាលនោះទេ ដើម្បីឱ្យតុលាការបានធ្វើការពិនិត្យ និងមានមូលដ្ឋានក្នុងសម្រេចសេចក្ដីនោះទេ គឺទាំងដើមចោទ និងមេធាវីតំណាងដោយអាណត្តិរបស់ដើមចោទមានចេតនាអូសបន្លាយពេលវេលានៅក្នុងនីតិវិធីនៃបណ្ដឹង និងមិនព្រមធ្វើការដាក់ភស្តុតាងជាឯកសារណាមួយមកកាន់តុលាការនោះឡើយ។ សកម្មភាព និងចេតនារបស់ភាគីដែលបានចូលរួមនៅក្នុងនីតិវិធីនៃបណ្ដឹង គប្បីតុលាការធ្វើការពិចារណាទៅលើមូលដ្ឋាននៃគោលការណ៍ទូទៅនៃក្រមនីតិវិធីរដ្ឋប្បវេណីគឺមាត្រា៩។ លើសពីនេះទៅទៀត ដោយផ្អែកលើគោលការណ៍តុលាការអកម្ម គឺតុលាការពុំមានកាតព្វកិច្ចធ្វើការស្រាវជ្រាវចំពោះអង្គហេតុ ដែលភាគីចុងចម្លើយបានលើកឡើង ហើយមិនមានឯកសារភស្តុតាងមកធ្វើការបញ្ជាក់នោះទេ។ ដូច្នេះ តុលាការនឹងធ្វើការពិចារណាសម្រេចចំពោះការស្នើសុំនានា និងសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយតាមគោលការណ៍ និងស្មារតីនៃច្បាប់ជាមូលដ្ឋាន។

៦. តាមរយៈពាក្យបណ្ដឹង និងការស្នើបន្ថែមកម្មវត្ថុនៃបណ្ដឹងរបស់ដើមចោទ ជាប្រភេទបណ្ដឹងរដ្ឋប្បវេណី ដែលដើមចោទ បានប្រើប្រាស់សិទ្ធិនៅក្រមនីតិវិធីរដ្ឋប្បវេណីដោយផ្អែកតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន និងគោលការណ៍នៃសិទ្ធិពឹងពាក់តុលាការ ឱ្យធ្វើការដោះស្រាយបណ្ដឹងទាមទារតាមមាត្រា ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះសិទ្ធិដែលត្រូវបានអះអាងថា មានការរំលោភបំពាន។



Scanned with CamScanner

៧. ម្យ៉ាងទៀត ទោះបីជាមាត្រា ១៦ មាត្រា ១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានផ្តល់ឆន្ទានុសិទ្ធិ ដល់តុលាការក្នុងការពិនិត្យភស្តុតាង និងសម្រេចអំពីបញ្ហាទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការក៏ដោយ ក៏តាមបញ្ញត្តិនៃគោលខណ្ឌទី ២ មាត្រា ៥៨៨ (ការធ្វើឱ្យនិរាករណ៍នូវច្បាប់ផ្សេងជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់ចំពោះបញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវចាត់ទុកថា គ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងក្រមនីតិវិធីរដ្ឋប្បវេណីចាប់ពីថ្ងៃដែលក្រមនេះ ត្រូវបានអនុវត្ត។ ដូច្នេះ តុលាការរដ្ឋប្បវេណី មានសិទ្ធិជម្រះក្តី ចំពោះការទាមទារតាមពាក្យបណ្តឹង ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ជួរហុង និងឈ្មោះ [redacted] ផានី និងពាក្យសុំបន្ថែមកម្មវត្ថុនៃពាក្យបណ្តឹង ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ផានី ទោះបីជាវិវាទរវាងភាគីជាវិវាទដីធ្លីដែលពុំទាន់បានធ្វើការចុះបញ្ជីក៏ដោយ ប៉ុន្តែវិវាទនេះគឺជាវិវាទដែលពាក់ព័ន្ធនឹងការកំណត់អំពីអត្ថិភាពនៃសិទ្ធិ ។

៨. តាមការពិនិត្យទៅលើភស្តុតាងដែលជាលិខិតបដិសេធរបស់លោក [redacted] ជាមេឃុំបន្ទាយដែក លេខ ០០១ ប.ដ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៧ បានបដិសេធ និងមោឃភាពទាំងស្រុង ចំពោះលិខិតផ្ទេរសិទ្ធិ និងប្រើប្រាស់ដីធ្លី របស់ឈ្មោះ [redacted] សុវណ្ណ ដែលបានលក់ និងផ្ទេរសិទ្ធិ ឱ្យទៅឈ្មោះ [redacted] ម៉េងឡុង លេខ ៦២២ ប.ដ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ដែលមានទំហំដី ១២៥.០០០,៤៧ ម៉ែត្រក្រឡា ដោយបានបញ្ជាក់នូវមូលហេតុថា ឈ្មោះ [redacted] សុវណ្ណ បានលួចដីរបស់ឈ្មោះ [redacted] ជួរហុង, ឈ្មោះ [redacted] ម៉េង, និងឈ្មោះ [redacted] ស្រីធំ លក់ឱ្យទៅឈ្មោះ [redacted] ម៉េងឡុង ដែលដីនោះ ស្ថិតនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដោយឈ្មោះ [redacted] សុវណ្ណ បានកុហកថា ដីនោះជាដីរបស់អង្គភាពភូមិភាគ មិនមានពាក់ព័ន្ធនឹងដីប្រជាពលរដ្ឋណានោះទេ។ នៅថ្ងៃនោះផងដែរ ខ្លួនជាមេឃុំបន្ទាយដែក មានបញ្ហាសុខភាព និងវ័យកាន់តែចាស់ផងនោះ មិនអាចចុះពិនិត្យទីតាំងដីជាក់ស្តែងបាន ហើយឈ្មោះ [redacted] សុវណ្ណ ក៏បានបរកេឈ្មោះលោកចៅហ្វាយស្រុកប្រាប់ថា ឱ្យមេឃុំ ចុះហត្ថលេខា និងបោះត្រាលើឯកសារដីខាងលើ។ លុះដល់ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៧ ខាងសាលាឃុំបានស៊ើបអង្កេត និងពិនិត្យឃើញថា ដីខាងលើនោះមានការពាក់ព័ន្ធនឹងឈ្មោះ [redacted] ជួរហុង ឈ្មោះ [redacted] ម៉េង និងឈ្មោះ [redacted] ស្រីធំ ដែលជាម្ចាស់ដី ហើយខាងសាលាឃុំក៏បានទាក់ទងទៅឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ម៉េងឡុង ដើម្បីឱ្យយកលិខិតផ្ទេរដីខាងលើមកសាលាឃុំវិញ ដើម្បីធ្វើការនិរាករណ៍លិខិតខាងលើចោល។ ប៉ុន្តែឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] ម៉េងឡុង មិនបានចូលខ្លួន និងយកលិខិតខាងលើមកសាលាឃុំទេ។ តាមខ្លឹមសារនៃការបញ្ជាក់នៅក្នុងភស្តុតាងជាឯកសារនេះ គឺអាចឲ្យតុលាការមានមូលដ្ឋានក្នុងការពិចារណា និងសម្រេចតាមការទាមទាររបស់សហដើមចោទ។

៩. ចំពោះការស្នើសុំឲ្យសាលក្រមនេះ មានអានុភាពអនុវត្តបណ្តោះអាសន្ន តុលាការនឹងធ្វើការពិចារណា និងសម្រេចតាមលក្ខខណ្ឌនៃមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

១០. ប្រាក់ប្រដាប់ក្តី តុលាការនឹងពិចារណាសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។



Scanned with CamScanner

## សេចក្តីសម្រេចបញ្ចប់

១. ពោយភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ៦២២ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ម៉េងឡុង ទំហំ ១២៥ ហិចតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

២. ពោយភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ៥០ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] លីសាន ទំហំ ១០ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៣. ពោយភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ៣៥១ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ធារ៉ូ ទំហំ ១៥ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៤. ពោយភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥២ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ឡាឌីន ទំហំ ១០ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៥. ពោយភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥៣ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] សុគន្ធា ទំហំ ២០ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៦. ពោយភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥៥ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ម៉េងឡុង ទំហំ ៣០ ហិចតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៧. ពោយភាពលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ៣៥៦ ប.ដ ដែលឈ្មោះ [redacted] សុវណ្ណ ប្រគល់សិទ្ធិឱ្យឈ្មោះ [redacted] ផាន់ណា ទំហំ ១៥ ហិកតា មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៨. ទទួលស្គាល់ដីដែលមានទំហំ ៥៥៧២១២ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិអង្គជ័យ ភូមិកណ្តាលលើ និងភូមិកណ្តាលក្រោម នៃឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលបានវាស់វែងជាមួយក្រុមចម្រុះរបស់ស្រុកដែលមាន ៖

ក. អ័ក្សអាប់ស៊ីស (X)៥១៣៩៥៣ និងកូអ័រដោណេ (Y)១២៥២៩៤០

ខ. អ័ក្សអាប់ស៊ីស (X)៥១៥០៥៨ និងកូអ័រដោណេ (Y)១២៥៧៩៩៣

គ. អ័ក្សអាប់ស៊ីស (X)៥១៥៥៧៣ និងកូអ័រដោណេ (Y)១២៥៧៩៩៦

ឃ. អ័ក្សអាប់ស៊ីស (X)៥១៥៥៧៤ និងកូអ័រដោណេ (Y)១២៥៧៩៩៦

ង. អ័ក្សអាប់ស៊ីស (X)៥១៥០៧៤ និងកូអ័រដោណេ (Y)១២៥៧២២៦

ច. អ័ក្សអាប់ស៊ីស (X)៥១៥០៧៥ និងកូអ័រដោណេ (Y)១២៥៧២២៦

ឆ. អ័ក្សអាប់ស៊ីស (X)៥១៣៩៦៩ និងកូអ័រដោណេ (Y)១២៥៧០៦៦ ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ផានី។



Scanned with CamScanner

៩. ឱ្យមន្ទីរសុរិយោដីធ្វើការចុះបញ្ជីដីដែលមានទំហំ **៥៥៧២១២** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិវង្គជ័យ ភូមិកណ្តាលលើ និងភូមិកណ្តាលក្រោម នៃឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ខាងលើនេះ មកជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ផានី។

១០. ច្រានចោលចំពោះការទាមទារឲ្យសាលក្រមមានអានុភាពអនុវត្តជាបណ្តោះអាសន្ន។

១១. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយឈ្មោះ [redacted] សុវណ្ណ ។

សាលក្រមនេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០។

*ទុកសិទ្ធិប្តឹងតក្នុងកំណត់ច្បាប់។*

**ចៅក្រម**

**ហត្ថលេខា និងត្រា៖** [redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ១១កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព ស ២៥៦៤

កណ្តាល, ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃចន្ទ ១១កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព ស ២៥៦៤

កណ្តាល, ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០

**ចៅក្រម**

[redacted]



Scanned with CamScanner